**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
*Kingdom of Wonder*

**ក្រសួងទេសចរណ៍**

លេខ ០០៤ ស.រ.ណ.ន

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៩

## សារាចរណែនាំ

## ស្តីពីការរៀបចំចំណាត់ថ្នាក់សណ្ឋាគារ

ផ្អែកលើគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការជម្រុញកិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍ និងក្នុងគោលបំណងគ្រប់គ្រង ពង្រឹងគុណភាពសេវាកម្មស្នាក់នៅ អោយមានលក្ខណៈកាន់តែសមស្របតាមនិយាមអន្តរជាតិ ជាពិសេសការផ្តល់ព័ត៌មានពិតប្រាកដអំពីស្ថានភាពនៃលក្ខណៈសម្បត្តិ របស់សណ្ឋាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដល់ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ ភ្ញៀវទេសចរ និងដើម្បីអនុវត្ត ប្រកាស លេខ ១០៥ ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ ក្រសួងទេសចរណ៍ធ្វើការណែនាំដូចខាងក្រោម :

១- សារាចរនេះត្រូវបានអនុវត្តចំពោះគ្រប់សណ្ឋាគារក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- សណ្ឋាគារដែលអាចទទួលការផ្តល់ចំណាត់ថ្នាក់បានត្រូវស្ថិតក្នុងលក្ខណៈសម្បត្តិ ដូចជា :

- មានអាជ្ញាបណ្ណទេសចរណ៍ ដែលមានសុពលភាព
- មានវិញ្ញាបនប័ត្រធានារ៉ាប់រង
- ស្លាកឈ្មោះសណ្ឋាគារត្រូវមើលឃើញច្បាស់ដោយមានអក្សរខ្មែរធំជាងអក្សរបរទេស ដែលត្រូវកំណត់ដោយឡែកពីក្រសួងទេសចរណ៍ ។

៣- ចំណាត់ថ្នាក់សណ្ឋាគារ ត្រូវផ្តល់ចាប់ពីថ្នាក់ផ្កាយ១ រហូតដល់ផ្កាយ៥ ដែលជាចំណាត់ថ្នាក់ខ្ពស់បំផុត ។ ក្រសួងទេសចរណ៍នឹងមានការកំណត់ដោយឡែក អំពីចំណាត់ថ្នាក់ ភូមិគ្រឹះទេសចរណ៍ ប៊ឹងហ្គាឡូ (Bungalow/Tourist Village), សណ្ឋាគារអាផាតម៉ិន (Hotel Apartment), ផ្ទះភ្ញៀវ (Tourist Guest House) ។

៤- នីតិវិធីនៃការរៀបចំចំណាត់ថ្នាក់សណ្ឋាគារ ត្រូវអនុវត្តតាមបែបបទដូចខាងក្រោម :

៤-១ ការបំពេញបែបបទសុំផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ ត្រូវធ្វើឡើងដោយអ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ តាមគំរូពាក្យសុំ និងលក្ខខណ្ឌផ្សេងៗ ដែលតម្រូវដោយក្រសួងទេសចរណ៍ ។

៤-២ រាល់ពាក្យស្នើសុំផ្តល់ចំណាត់ថ្នាក់ ឬសំណុំបែបបទផ្សេងៗដែលពាក់ព័ន្ធនឹងការសុំចំណាត់ថ្នាក់សណ្ឋាគារ ត្រូវទាក់ទង ឬដាក់ពាក្យសុំនៅក្រសួងទេសចរណ៍ នៅគណៈកម្មការរៀបចំចំណាត់ថ្នាក់សណ្ឋាគារ "គ.រ.ច" ។ ការដាក់ពាក្យសុំធ្វើចំណាត់ថ្នាក់សណ្ឋាគារត្រូវបង់នៃថ្ងៃធ្វើចំណាត់ថ្នាក់សណ្ឋាគារទៅតាមកម្រិតចំណាត់ថ្នាក់ដែលបានស្នើសុំ ។ មន្ទីរទេសចរណ៍រាជធានី-ខេត្ត អាចត្រូវចាត់តាំងជាកន្លែងទទួលពាក្យសុំធ្វើចំណាត់ថ្នាក់សណ្ឋាគារដែលស្ថិតនៅក្នុងតំបន់នោះ ។ ទម្រង់បែបបទទាំងអស់ត្រូវមានការចុះលេខ និងកាលបរិច្ឆេទប្រគល់-ទទួលត្រឹមត្រូវ ។

៤-៣ ក្នុងរយៈពេល ២០ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីទទួលបាននូវសំណុំបែបបទសុំចំណាត់ថ្នាក់សណ្ឋាគារត្រឹមត្រូវ គ.រ.ច ត្រូវចាត់ក្រុមការងារចុះត្រួតពិនិត្យសណ្ឋាគារជាក់ស្តែងដល់មូលដ្ឋានអាជីវកម្ម ដើម្បីប្រមូលទិន្នន័យ និងរៀបចំវាយតម្លៃអំពីចំណាត់ថ្នាក់សណ្ឋាគារ ។ ការចុះត្រួតពិនិត្យអាចត្រូវធ្វើលើសពីមួយដង ( មិនលើសពីបីដងក្នុងវគ្គនិមួយៗ ) បើសិនជាមានការចាំបាច់ ។

៤-៤ រាល់ការចុះត្រួតពិនិត្យសណ្ឋាគារ ក្រុមការងារនៃ គ.រ.ច ត្រូវមានបណ្ណ សម្គាល់ និងត្រូវបង្ហាញជូនអ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារនូវលិខិតបេសកកម្មរបស់ គ.រ.ច ។ ក្រុមការងារនៃ គ.រ.ច ត្រូវធ្វើកំណត់ហេតុ និងរបាយការណ៍ការងារចុះត្រួតពិនិត្យ ដោយផ្តល់យោបល់អំពីលទ្ធផល នៃការវាយតម្លៃផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ ។

៤-៥ គ.រ.ច មានសិទ្ធិក្នុងការពិនិត្យ និងផ្តល់ចំណាត់ថ្នាក់ជំហានដំបូង ដោយត្រូវឈរលើមូលដ្ឋានពិចារណាសំខាន់ ៤ យ៉ាងគឺ :

- សំណុំបែបបទសុំធ្វើចំណាត់ថ្នាក់សណ្ឋាគារ
- កំណត់ហេតុចុះត្រួតពិនិត្យសណ្ឋាគាររបស់ក្រុមការងារ
- របាយការណ៍វាយតម្លៃរបស់ក្រុមការងារ
- ឯកសារ និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀតដែលចាំបាច់ ។

គ.រ.ច ត្រូវចេញសេចក្តីជូនដំណឹងជាលាយលក្ខអក្សរជូនអ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ អំពីការទទួលស្គាល់ស្តង់ដារជំហានដំបូងក្នុងរយៈ ២០ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីក្រុមការងារបានចុះត្រួតពិនិត្យ ។ ក្រោយរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ នៃសេចក្តីជូនដំណឹងនេះបើគ្មានការជំទាស់ជាលាយលក្ខអក្សរពីអ្នកស្នើសុំនោះទេ ការប្រកាសលទ្ធផលទទួលស្គាល់ចំណាត់ថ្នាក់សណ្ឋាគារជំហានដំបូងត្រូវចាត់ទុកជាបានការ ។ ក្រសួងទេសចរណ៍នឹងចេញសេចក្តីសម្រេចទទួលស្គាល់ចំណាត់ថ្នាក់សណ្ឋាគារជាផ្លូវការ មិនលើសពីរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ។

៤-៦ អ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ មានសិទ្ធិតវ៉ាជំទាស់ជាលាយលក្ខអក្សរ ចំពោះលទ្ធផលចំណាត់ថ្នាក់សណ្ឋាគារជំហានដំបូងមក មិនអោយហួសរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃចេញសេចក្តីជូនដំណឹង ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ ។ ពេលបានទទួលពាក្យតវ៉ាជំទាស់ជាផ្លូវការ គ.រ.ច ត្រូវធ្វើការពិនិត្យ និងរៀបចំក្រុមការងារចុះទៅត្រួតពិនិត្យ និងវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារជាថ្មី ។

៤-៧ ក្នុងករណីសណ្ឋាគារពុំអាចបំពេញបាន តាមកម្រិតប្រព័ន្ធស្តង់ដារអប្បរមា ដូចមានចែងក្នុងអនុក្រឹត្យលេខ ១៦ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ នោះ គ.រ.ច ត្រូវធ្វើលិខិតឆ្លើយតប និងបញ្ជាក់អំពីមូលហេតុច្បាស់លាស់ ជូនដល់អ្នកស្នើសុំ ។

៥- សណ្ឋាគារដែលបានទទួលស្គាល់ចំណាត់ថ្នាក់ ត្រូវធ្វើការចាត់ថ្នាក់ឡើងវិញ ក្នុងរយៈពេលមិនលើសពីពីរឆ្នាំ ។ ក្នុងករណីដែលសណ្ឋាគារណាខិតខំលើកកំពស់គុណភាពមូលដ្ឋានអាជីវកម្ម បំពាក់សម្ភារៈបរិក្ខារ និងសេវាកម្មផ្សេងៗ ឬមានការធ្លាក់ចុះដោយមិនអាចរក្សាបាននូវកម្រិតប្រព័ន្ធស្តង់ដារចំណាត់ថ្នាក់ដែលបានទទួលស្គាល់ ឬដោយមានការស្នើសុំ

ពីស្ថាប័នមានសមត្ថកិច្ច ឬអង្គការផ្សេងៗ នោះក្រសួងទេសចរណ៍នឹងពិនិត្យវាយតម្លៃចំណាត់ថ្នាក់ឡើងវិញ (តម្លើង បញ្ចុះថ្នាក់ ព្យួរ បដិសេធ) ស្របតាមទិដ្ឋភាពជាក់ស្តែងរបស់សណ្ឋាគារនោះ។

៦- គ.វ.ច ត្រូវធ្វើលិខិតជូនដំណឹងដល់អ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ ដែលប្រើប្រាស់ចំណាត់ថ្នាក់សណ្ឋាគារហួសសុពលភាព ។ ករណីដែលនៅតែបន្តការប្រើប្រាស់ចំណាត់ថ្នាក់ហួសសុពលភាព នោះចាត់ទុកជាខុសច្បាប់ ។

៧- ការស្នើសុំចំណាត់ថ្នាក់សណ្ឋាគារត្រូវធ្វើនៅពេលសុំផ្តល់ ឬបន្តអាជ្ញាបណ្ណទេសចរណ៍ ។ ក្នុងករណីចាំបាច់អាជីវករអាចស្នើសុំផ្តល់ចំណាត់ថ្នាក់សណ្ឋាគារនៅក្នុងសុពលភាពនៃអាជ្ញាបណ្ណទេសចរណ៍ ។

៨- ស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារត្រូវចេញដោយក្រសួងទេសចរណ៍ រីឯថ្លៃស្លាកសញ្ញា ចំណាត់ថ្នាក់គឺជាបន្ទុករបស់ម្ចាស់ ឬអ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ ។

ទទួលបាននូវសារាចរណែនាំនេះ មន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជធានី-ខេត្ត ដើម្បីចាត់តាំងផ្សព្វផ្សាយដល់ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារទាំងអស់អនុវត្តខ្លឹមសារសារាចរណែនាំនេះអោយមានប្រសិទ្ធភាពខ្ពស់ និងរួមចំណែកអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាប្រកបដោយនិរន្តរភាព ។

ថោង ខុន

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី-ខេត្ត ដើម្បីជូនជ្រាប
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត ដើម្បីមុខការ
- ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ